# វិធីដាំមៀន/គាវ៉ៃន

## ១. ការរៀបចំរណ្ដៅ:

- ត្រូវជីករណ្ដៅ ៦តឹកបួនជ្រុង និង ជំរៅ ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយក្នុងរណ្ដៅ។
- ត្រូវដាក់ផេះ ឬ អង្កាម, កំប្លោក, ចំបើង ពុក, អាចម៍មាន់ឬអាចម៍ជ្រូក ឬអាចម៍គោមួយស្រទាប់កំរាស់១តឹក រួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះ រហូតទាល់តែពេញរណ្ដៅ។




- ត្រូវទុករណ្ដៅរៀបចំហើយក្នុងរយៈពេល ២ ទៅ ៣អាទិត្យ។



- ចំងាយពីរណ្ដៅមួយទៅរណ្ដៅមួយ មានប្រវែង ៦ ម៉ែត្រ។

## ២. ការដាំ:

- កូនមៀនត្រូវរក្សាផ្សាំទុក ១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដី និងឫស។
- ជញ្ជូនកូនមៀនដាក់ក្បែររណ្ដៅ ទាំងអស់។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- ដាំកូនមៀនក្នុងរណ្ដៅ កប់ដីកន្ទោងស្មើមាត់រណ្ដៅ រួចយកមែកឈើដោតក្បែរចងទប់ ជាមួយកូនមៀនការពារខ្យល់បក់។
- រោយដីបន្តិចម្ដងៗដោយសង្កត់ថ្នមៗជុំវិញដីកន្ទោង ហាមសង្កត់លើដីកន្ទោងកូនមៀនដែលបណ្ដាលអោយដាច់ឫស។



## ៣. ការថែទាំ និងដាក់ជី:

- ខែវស្សារត្រូវពូនគល់ការពារទឹកជាំនៅគល់បណ្ដាលអោយរលួយឫស។



- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើជីអាចម៍មាន់ ឬអាចម៍ជ្រូក ឬអាចម៍គោលាយជាមួយអង្កាមពុក, ចំបើង ឬកំប្លោករលួយកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនមៀនមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសំលាប់សត្វល្អិត (ណាហ្គា) ។
- នៅពេល ផ្លែមៀនមានទំហំប៉ុនមេដៃយើងត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត(ណាហ្គា)ទៅលើផ្លែដើម្បីការពារដង្កូវស៊ីផ្លែពេលវាទុំ។



## ៤. ការស្រោចទឹក:

- កូនមៀនអាយុតិចជាង២ឆ្នាំ ត្រូវស្រោចទឹក ១ដងក្នុង១អាទិត្យនៅរដូវប្រាំង។
- យើងត្រូវស្រោចទឹកតែម្ដងគត់នៅពេលវាកំពុងផ្កា។

## ៥. ការកាត់តែងមែកៈ

- ត្រូវកាត់ត្រួយចុងចេញនៅឆ្នាំទីមួយ ។
- ត្រូវកាត់មែកមិនសូវល្អចេញ រៀងរាល់ឆ្នាំដោយទុកតាមប្រព័ន្ធ ១-៣-៦-១៨ (ដើម១-មែកធំ៣-ខ្នែងធំ៦ និងខ្នែងត្រួយ១៨) បើអាច ធ្វើបានជាការល្អ ។



កាត់តែងមែកតាមប្រព័ន្ធ ១-៣-៦-១៨

## ៦. ការជំរុញផ្លែផ្កាៈ

- ពេលដើមមៀនអាយុ ៤ឆ្នាំយើងគួរប្រើជីប៉ូតាស្យូមនីត្រាត ០,៥០គក្រ/១ដើម ។ អាយុ ៥ឆ្នាំ ១គក្រ និង៧ឆ្នាំ ១.៥០គក្រ/១ដើម
- យកជីនេះលាយជាមួយទឹក រួចស្រោចជុំវិញគល់មៀន ដោយស្រោច២ដងបញ្ច្រាស់ទិសគ្នាក្នុងពេលតែមួយ ។
- រយៈពេលប្រហែល១ខែក្រោយចាក់ជី យើងឃើញដើមមៀនចេញផ្កា ។



## ៧. ការប្រមូលផលៈ

- មិនត្រូវបេះផ្លែមៀនទំលាក់លើដីទេ ។
- ត្រូវបេះផ្លែមៀន អោយមានជាប់ទង ឬស្មែងជាការប្រសើ ។

**អាចរកទិញកូនមៀនបានតាមរយៈ**

១- អ្នកស្រី **ជា ធារិទ្ធ**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរស្ពានទឹកវិល, ខ័ណ្ឌ-ក្រុង សៀមរាប, ទូរស័ព្ទលេខ: 012 35 10 30/017 68 84 49

២- លោក **គឹម សុធា**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនបុប្ផអង្គរ, ក្រុង សៀមរាប, ទូរស័ព្ទលេខ: 012 98 06 23

៣- លោក **គឹម ឈុំ**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនច្បារអេដែន, ក្រុង សៀមរាប, ទូរស័ព្ទលេខ: 012 31 20 55

៤- លោក **វ៉ាន់ ហឿន**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរផ្សារអង្គ្រង, ស្រុកប្រាសាទបាគង ខេត្តសៀមរាប, ទូរស័ព្ទលេខ: 012 70 80 43

៥- អ្នកស្រី **គឹម សាវេត**, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ភូមិស្ពានជ្រាវ, ខ័ណ្ឌ-ក្រុង សៀមរាប, ទូរស័ព្ទលេខ: 089 80 54 66

**សំរបសំរួលដោយ**
**កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប**
Facilitated by RED - Green Belt Siem Reap



# ភាពជោគជ័យក្នុង ការដាំមៀន/គាវ៉ែន



## ការណែនាំអនុវត្តន៍ជាក់ស្តែង ដោយៈ

លោក **ធន់ សំអុល**. ដាំមៀន និងលក់ពូជ
អាស័យដ្ឋានៈ ឃុំអណ្តើកហែប, ស្រុករតនៈមណ្ឌល, ខេត្តបាត់ដំបង, ទូរស័ព្ទ: ០១២ ៣២ 00 ៣៥